| | |
|---|---|
| **ទុត្ថា**<br><br>**"នេះគឺជារឿងរ៉ាវអំពីស្ត្រី២នាក់ដែលកាលពីក្មេង ជីវិតរបស់ពួកគាត់ត្រូវគេបំផ្លាញ "**<br><br>**ទុត្ថា**<br>ខ្ញុំកំពុងស្ថិតនៅឯវាលស្រែ។<br>ខ្ញុំបានឃើញស្ត្រីម្នាក់ ។<br>គាត់មានអាយុ ៤៣ឆ្នាំ ។<br>គាត់តែងតែនឹកនាដល់ឪពុករបស់គាត់ខ្លាំងណាស់។<br>សូមអញ្ជើញស្តាប់រឿងរ៉ាវរបស់ស៊ីណា។<br><br>**ស៊ីណា**<br>នេះគឺជាឆ្នាំ ១៩៧៦។<br>ខ្ញុំមានអាយុ ១០ឆ្នាំ។<br>គេយកឪពុកខ្ញុំទៅមន្ទីរពេទ្យ។<br>ពុករបស់ខ្ញុំ គាត់មានសក់រួញយ៉ាងស្រស់សង្ហា។<br>ពុកដ៏រឹងមាំរបស់ខ្ញុំ គាត់មានសំបុរសណ្តែកបាយ។<br>ពុកមានជំងឺហើម....មនុស្សយើងតែងតែហើមអញ្ចឹង<br>នៅពេលដែលគ្មានអីហូប។<br>នេះគេហៅថា ជំងឺដែលបណ្តាលមកពីភាពអត់ឃ្លាន។<br>ខ្លួនពុកហើមស្រក១។<br>ពុកស្រែអោយគេជួយ......ជួយផង......ជួយផង....!<br>ខ្ញុំឈឺពោះខ្លាំងណាស់។ | **ឱ..ព្រះជាម្ចាស់ហើយ...**<br>**ហេតុអ្វីបានជាប្រទេសកម្ពុជាទៅវិញ...?** |

| | |
|---|---|
| ពេទ្យក្មេងម្នាក់ចេញមក ហើយស្រែកអោយពុក | **(សំលេងភ្លេងខ្លាំងចាប់ផ្តើម និងលេងតិចៗ ពេលសុវណ្ណាកំពុងនិយាយ)** |
| **សុវណ្ណា**<br>**"ថ្លង់ណាស់! យើងដេកមិនលក់ទេ!"**<br><br>**ស៊ីណា**<br>ម៉ែសំពះអង្វរពេទ្យនោះ **"មិត្តបង.....សូមជួយប្តីខ្ញុំផង .....គាត់ឈឺពោះខ្លាំងណាស់។ "**<br>ពេទ្យនោះលូកដៃចូលក្នុងហោប៉ៅ យកថ្នាំពណ៌ខ្មៅៗ មួយក្តាប់ ហើយក៏ដើរចេញទៅ។<br>ម៉ែអោយថ្នាំទៅពុក ប៉ុន្តែថ្នាំនោះមិនបានជួយអោយពុកបាត់ឈឺពោះនោះទេ។<br>ពុកថ្ងូរឈឺ។<br>ពេទ្យនោះចេញមកម្តងទៀត ហើយស្រែកអោយពុក | |
| **សុវណ្ណា**<br>**"ហើយម៉េចក៏ស្រែកអីខ្លាំងម៉េះ?! ចង់ងាប់អ្វេះ?!"**<br><br>**ស៊ីណា**<br>ពុកស្រែកឈឺ។ ភ្នែកពុកឡើងលៀន។<br>ម៉ែអង្វរពេទ្យ **"មិត្តបងអើយ.....សូមជួយប្តីខ្ញុំផង.... គាត់កាន់តែឈឺខ្លាំងឡើងៗហើយ...."** | **(សំលេងភ្លេងខ្លាំង លេងពេលសុវណ្ណានិយាយ)** |

| | |
|---|---|
| ពេទ្យនោះក៏ដើរសំដៅមកពុកដោយមានកាន់ថ្នាំមួយស៊ីរ៉ាំងធំ ហើយចាក់ថ្នាំចូលទៅក្នុងសាច់ពុក។<br>ពុកបាត់មាត់ឈឹង ហើយនៅស្ងៀម។<br>ម៉ែ ត្រកង និងឱបពុក។<br>ពេទ្យបញ្ចាំងពិលដាក់មុខម៉ែ.........<br><br>**សុវណ្ណា**<br>**" នែ៎! ហើយមិត្តឯងធ្វើអីហ្នឹង?មិនឃើញប្តីមិត្តឯងស្លាប់ហើយទេ អ្ហែ៎?ចង់នៅឱបខ្មោចដល់អង្កាល់ទៀត? "**<br><br>**ស៊ីណា**<br>ម៉ែអត់យំទេ។<br>ម៉ែគ្មាននិយាយស្តីអីទាំងអស់។<br>ខ្ញុំមានអាយុ ១០ឆ្នាំ។ ចាប់ពីថ្ងៃនោះមក ក្នុងខ្លួនខ្ញុំលែងមានអ្វីទាំងអស់។<br><br>**ទុក្ខា (និពន្ធកំណាព្យដោយលោក សំអ៊ូ អឿ "ទំនួញភរិយា ")**<br><br>បងអើយ អើយបង !<br>បងស្លាប់ចោលអូន ជីវិតបងសូន្យ | **(សំលេងភ្លេងខ្លាំង លេងពេលសុវណ្ណានិយាយ)** |

| | |
|---|---|
| ចោលអូនឯកឯង កណ្ដាលលំហលោកា<br>ពីពេលនេះទៅ ។<br><br>**(អ្នកសំដែងទាំងបួនបន្ទរ)**<br>ធ្លាប់រួមធ្លាប់រស់ ចិត្តបងតែងស្មោះ<br>ស្ម័គ្រលើអូនពៅ ពេលនេះបងស្មៀម<br>ពៅទុក្ខខ្លោចផ្សា ។<br><br>អូនខមាលាទោស អ្វីអូនធ្វើខុស<br>អូនកប់បងហើយ អូនលារៀមរ៉ា<br>ជួបសុគតិភព ។<br><br>**ទុត្តា**<br>ខ្ញុំឃើញស្ត្រីម្នាក់ទៀត។<br>នាងក្រាបពីក្រោយបាវស្រូវ។<br>អ្នកស្រីសម្ផស្សមានអាយុ ៤៨ឆ្នាំ។<br>គាត់រស់ដោយស្ពាយនូវភាពអាម៉ាស់ជាប់នឹងខ្លួន ។<br><br>**ទុត្តា**<br>**អ្នកស្រីសម្ផស្ស ហេតុអីបានជាអ្នកពួននៅពីក្រោយ**<br>**បាវស្រូវនេះទៅវិញ ?**<br><br>**សុវណ្ណា :**<br>ខ្ញុំពួនពីព្រោះខ្ញុំខ្មាសគេ ។ | |

| | |
|---|---|
| **សុខលី :**<br>តើអ្នកបានស្តាប់រឿងរបស់ស៊ីណាដែររឺទេ?<br><br>**សុវណ្ណា :**<br>ខ្ញុំបានលឺអស់ហើយ....<br><br>**វុត្ថា**<br>អ្នកស្រីសម្ហស្សបើអ្នកបានជួបក្មេងស្រីដែលអង្គុយក្បែរឪពុករបស់នាងដែលស្លាប់ជាមួយនឹងម្តាយដែលស្ងប់ស្ងាត់របស់នាង តើអ្នកនឹងធ្វើដូចម្តេច ?<br><br>**សុវណ្ណា :**<br>ខ្ញុំនឹងដើរចូលទៅក្នុងផ្ទះ ហើយទាញទ្វារបិទតិចៗ ។<br><br>**វុត្ថា :**<br>ស៊ីណា...បើអ្នកបានជួបពេទ្យដែលស្រែកដាក់ម៉ែអ្នកកាលពីមុន តើអ្នកនឹងធ្វើយ៉ាងម៉េចទៅ?<br><br>**ស៊ីណា :**<br>ខ្ញុំនឹងរត់ចេញអោយឆ្ងាយ ។<br>ខ្ញុំនឹងនៅស្ងៀមស្ងាត់ដូចម៉ែខ្ញុំអញ្ចឹង ។<br><br>**វុត្ថា :**<br>ស៊ីណា...មើលនេះនែ៎...គាត់នេះគឺជាអ្នកគ្រូពេទ្យ ។ | |

| | |
|---|---|
| តើអ្នកនៅចាំគាត់ដែរទេ ?<br>ខ្ញុំគិតថា គាត់ក៏ចង់និយាយរឿងគាត់ប្រាប់យើងដែរ ។<br><br>**សុវណ្ណា**<br>នេះគឺជាឆ្នាំ ១៩៧៦។<br>ខ្ញុំមានអាយុ ១៥ឆ្នាំ។<br>ពេលនោះមានក្មេងស្រីជាច្រើននាក់បានមកធ្វើជាគ្រូពេទ្យដើម្បីជួយដល់បដិវត្តន៍។<br>ខ្ញុំសប្បាយចិត្តខ្លាំងណាស់ពីព្រោះនេះគឺជាសុបិន្តរបស់ខ្ញុំ ។ ខ្ញុំជាអ្នកមើលថែអ្នកជំងឺ ។ខ្ញុំបានក្លាយជាគ្រូពេទ្យនៅអាយុ ១៥ឆ្នាំប៉ុណ្ណោះ។ ខ្ញុំខំធ្វើការណាស់។ ខ្ញុំមានមោទនភាពមែនទែន ។ គេថែមទាំងអនុញ្ញាតិអោយខ្ញុំចាក់ថ្នាំអោយអ្នកជំងឺទៀត ។<br>ប៉ុន្តែបន្តិចក្រោយមកខ្ញុំមើលឃើញថា ខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់ ។ មន្ទីរពេទ្យនោះមិនបានធ្វើការទៅតាមអ្វីដែលមន្ទីរពេទ្យគួរធ្វើនោះទេ។ពួកយើងធ្វើការនៅទីនោះ គឺដើម្បីតែបើកភ្នែកមើលមនុស្សស្លាប់តែប៉ុណ្ណោះ ។ ពួកយើងគ្មានអ្វីអោយអ្នកជំងឺទាល់តែសោះ ។ ថ្នាំសង្កូវអ្វីក៏គ្មាន។ មានតែថ្នាំដែលមានរាងដូចអាចម៍ទន្សាយតែប៉ុណ្ណោះ។ វាគ្មានជួយអ្វីបាននោះទេ។ ទាំងអស់នេះសុទ្ធតែជាកំហុស។<br>ខ្ញុំមានអារម្មណ៍ច្របូកច្របល់ហើយខឹងសម្បារ។<br><br>ខ្ញុំខឹងខ្លាំងណាស់។ ខ្ញុំចង់វាយគ្រែ ខ្ញុំចង់វាយអ្វីៗគ្រប់ | |

| | |
|---|---|
| យ៉ាងទាំងអស់។ ខ្ញុំស្អប់ខ្មែរក្រហម។ខ្ញុំស្អប់អ្នកជំងឺ<br>ដែលស្លាប់ម្នាក់ហើយម្នាក់ទៀត។ ខ្ញុំចង់រត់គេចតែវា<br>មិនអាចទៅរួច។ ខ្ញុំបានធ្លាក់ក្នុងអន្ទាក់នៃស្ថានភាពដ៏<br>អាក្រក់នេះ។<br>ថ្ងៃមួយ ខ្ញុំធ្វើអោយសុីរាំងមួយធ្លាក់ដោយអចេតនា ។<br>នោះគឺជាកំហុសមួយដ៏ធំ ។ប្រធានពេទ្យចោទខ្ញុំថាជា<br>ជនក្បត់ ហើយគាត់ព្រមានថា បើខ្ញុំធ្វើអោយធ្លាក់<br>សុីរាំងម្តងទៀត គេនឹងយកខ្ញុំទៅរៀនសូត្រ ។<br>តាំងពីថ្ងៃនោះមក ខ្ញុំចាំតែស្តាប់បញ្ជាគេរហូត ។<br>ខ្ញុំក្លាយខ្លួនជាមនុស្សយន្តអញ្ចឹង — ក្នុងដៃ មានថ្នាំ<br>អាចម៍ទន្សាយនិងសុីរាំង ។<br><br>ទីបំផុតពួកយើងត្រូវបានរំដោះ។ ខ្ញុំបានត្រលប់ទៅ<br>ស្រុកកំណើតវិញ។ បន្តិចក្រោយមកខ្ញុំក៏រៀបការ ។ ខ្ញុំ<br>មិនបានក្លាយខ្លួនទៅជាពេទ្យស្រីម្នាក់ដូចការដែលខ្ញុំប៉ង<br>ស្រម៉ៃពីក្មេងនោះទេ។ ប្តីខ្ញុំជាមនុស្សស្ងប់ស្ងាត់ម្នាក់<br>ហើយពួកយើងមានកូនដែលប្រកបដោយគន្លងធម៌ល្អ<br>យើងរស់នៅយ៉ាងស្ងប់ស្ងាត់ ។<br><br>**វុត្ថា :**<br>អ្នកស្រីសម្ទស្ស....អ្នកអាចនិយាយទៅកាន់សុីណាបាន<br>ទេថា អ្នកសោកស្តាយណាស់ដែលមិនបានជួយឪពុក<br>គាត់ ? | **ចាញ់បោក....ចាញ់បញ្ឆេត...(វុត្ថានិយាយ)** |

| | |
|---|---|
| **សុវណ្ណា ៈ**<br>ខ្ញុំអាចធ្វើអីបានទៅយើងគ្មានអីផ្តល់អោយពួកគាត់ទេ។ អង្ករមួយកំប៉ុងសំរាប់គ្នា២០នាក់.....អញ្ចឹងហើយបានជាពួកគេស្លាប់ ។ បើទោះបីជាមានថ្នាំ ក៏មិនអាចជួយជីវិតពួកគេបានដែរ។ ខ្ញុំអាចធ្វើអីបានទៅ......ខ្ញុំដូចជាសត្វក្នុងទ្រុងអញ្ចឹង ។<br><br>**ទុត្ថា ៈ**<br>អ្នកគួរតែនិយាយប្រាប់ស៊ីណាថាអ្នកសូមទោសគាត់ទៅ<br><br>**សុវណ្ណា ៈ**<br>អោយខ្ញុំសូមទោសផងដោយសារកាលណោះពួកយើងគ្មានថ្នាំហើយខ្ញុំគ្មានសិទ្ធធ្វើអ្វីទាំងអស់ ។<br><br>**ទុត្ថា ៈ**<br>ស៊ីណា......!តើអ្នកទទួលយកការសូមទោសនេះដែរឬអត់?<br><br>**ស៊ីណា ៈ**<br>ខ្ញុំដឹងថា ខ្ញុំគួរតែអត់ទោសអោយអ្នកឯងដែរ។ ប៉ុន្តែអ្នកបានសម្លាប់ឳពុកខ្ញុំ និងស្រែកគំហកអោយម្តាយខ្ញុំ។ ខ្ញុំពិបាកសម្រេចចិត្តណាស់...ខ្ញុំមិនដឹងត្រូវដោះស្រាយជាមួយស្ថានភាពនេះ យ៉ាងម៉េចទេ។ ខ្ញុំមិនដឹងនិយាយយ៉ាងម៉េចនោះទេ ។ | **ចាកចេញពីរង្វាស់នៃពេលវេលាសំដៅទៅរករង្វង់នៃសេចក្តីស្រលាញ់។** |

| | |
|---|---|
| **សុវណ្ណា ៖**<br>បេះដូងខ្ញុំខុសប្លែកពីធម្មតា។ បេះដូងខ្ញុំស្រាប់តែគាំង។ ក្នុងមួយជីវិតខ្ញុំនេះ ខ្ញុំខ្មាសខ្លួនឯងណាស់ ហើយខ្ញុំក៏មិនដែលភ្លេចដែរ ។ នេះគឺជាលើកទីមួយហើយដែលខ្ញុំនិយាយអំពីដំណើររឿងខ្ញុំ ។<br>អរគុណណាស់ ។<br>អ្នកបានទម្លាយរឿងដែលខ្ញុំលាក់ក្នុងចិត្តកន្លងមក ។<br>ខ្ញុំមានសង្ឃឹម....គឺក្តីសង្ឃឹមតិចតួច ដែលគេនឹងអត់ទោសអោយខ្ញុំ ។ | **សំលេងបេះដូង** |
| **ស៊ីណា ៖**<br>ខ្ញុំព្យាយាមអភ័យទោស ។ ខ្ញុំចង់អភ័យទោសណាស់ ។ ប៉ុន្តែយើងមិនត្រូវបំភ្លេចនូវអ្វីដែលបានកើតឡើងនោះទេ ។ បើយើងបំភ្លេច គឺហាក់ដូចជាយើងបាត់បង់ឪពុកម្តាយ កូន បងប្អូន មីងមា ដោយទទេៗអញ្ចឹង ។ | **ចាកចេញពីរង្វាស់នៃពេលវេលាសំដៅទៅរករង្វង់នៃសេចក្តីស្រលាញ់។**<br><br>**សំលេងបេះដូង**<br><br>**ភ្លេង ទន្ទេឈាម** |